- ត្រូវធ្វើតេស្តជាប្រចាំរបស់អ្នក រួមទាំងការធ្វើតេស្តឈាម និងអ៊ុលត្រាសោន តាមបញ្ជារបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក។
- ប្រាប់វេជ្ជបណ្ឌិតរបស់អ្នកមុននឹងលេបថ្នាំធ្វើពីរុក្ខជាតិ ឬថ្នាំបុរាណ ឬថ្នាំដទៃទៀត។ ថ្នាំទាំងនេះអាចប៉ះពាល់ដល់ថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B របស់អ្នក។

## យោបល់គន្លឹះសម្រាប់ការលេបថ្នាំ៖

- ដាក់ម៉ោងរោទិ៍នៅលើទូរសព្ទរបស់អ្នក ដើម្បីរម្លឹកអ្នកឱ្យលេបថ្នាំរបស់អ្នកនៅពេលដូចគ្នាជារៀងរាល់ថ្ងៃ។
- និយាយជាមួយឱសថការីរបស់អ្នកអំពីកញ្ចប់ Webster (ប្រអប់ថ្នាំដែលបានរៀបចំទុកជាមុន) ប្រសិនបើអ្នកលេបថ្នាំផ្សេងទៀតនៅពេលផ្សេងៗគ្នា។
- ស្នើសុំឱសថការីរបស់អ្នកឱ្យរក្សាវេជ្ជបញ្ជារបស់អ្នក និងរម្លឹកអ្នកនៅពេលអ្នកត្រូវទៅយកថ្នាំបំពេញប្រអប់ថ្នាំ (យកថ្នាំបន្ថែម)។
- វេជ្ជបណ្ឌិត គិលានុបដ្ឋាក ឬឱសថការីអាចប្រើសេវាកម្មបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ ប្រសិនបើអ្នកត្រូវការជំនួយផ្នែកភាសា។
- តើមិនមានកាតមេឌីឃែរ (Medicare Card)ឬ? - អ្នកអាចទិញឱសថនានាបានតាមអនឡាញពីបរទេស។




- Have your regular tests including blood tests and ultrasounds as ordered by your doctor or nurse.
- Let your doctor know before taking herbal or traditional medicines or any other medicines. They may affect your hepatitis B medication.

## Tips for taking the medication:

- Set an alarm on your phone to remind you to take your medication at the same time every day.
- Talk to your pharmacist about a Webster-pak (a pre-arranged medication container) if you take other medications at different times.
- Ask your pharmacist to keep your prescription and remind you when it is due for refill (get more).
- Doctors, nurses, or pharmacists can access free interpreter services if you need help with language.
- Do not have a Medicare Card? – You can access medicines online from overseas.

| | |
|---|---|
| ឈ្មោះវេជ្ជបណ្ឌិត/គិលានុបដ្ឋាករបស់អ្នក៖ | |
| ឈ្មោះគ្លីនិករបស់អ្នក៖ | |
| លេខទូរសព្ទគ្លីនិក៖ | |

## ទាក់ទងយើង

សម្រាប់ព័ត៌មានបន្ថែម អ្នកអាចទាក់ទង Love Health – ជំងឺរលាកថ្លើម មេរោគហ៊ីវ/ជំងឺអេដស៍ និងកម្មវិធីសុខភាពផ្លូវភេទនៅក្រុមប្រឹក្សាសហគមន៍ជាតិភាគតិចនៃរដ្ឋឃ្វីនស្លែន (ECCQ) តាមទូរសព្ទលេខ 3844 9166 health@eccq.com.au ឬចូលទៅកាន់គេហទំព័រ www.eccq.com.au/bbv

ទូរសព្ទ៖ **3844 9166**
អ៊ីមែល៖ **health@eccq.com.au**
គេហទំព័រ៖ **www.eccq.com.au/bbv**

ធនធាននេះត្រូវបានផលិតដោយ ECCQ ដោយបានផ្តត់ផ្គង់មូលនិធិពី Queensland Health ដោយសហការជាមួយមន្ទីរពេទ្យ Logan, Royal Brisbane និង Women's, Mater, Princess Alexandra Hospitals, QuIHN និង GESA

ព័ត៌មាននៅក្នុងខិត្តប័ណ្ណព័ត៌មាននេះ គឺមានលក្ខណៈទូទៅ។
គ្រូពេទ្យថែទាំសុខភាពរបស់អ្នកនឹងផ្តល់ដំបូន្មានជាក់លាក់ទាក់ទងនឹងតម្រូវការសុខភាពផ្ទាល់ខ្លួនរបស់អ្នក។
បោះពុម្ពផ្សាយនៅខែមេសា ឆ្នាំ2024

| | |
|---|---|
| Your Doctor/Nurses Name: | |
| Your Clinic Name: | |
| Clinic Phone Number: | |

## Contact Us

For more information you can contact Love Health – Hepatitis, HIV/AIDS and Sexual Health Program at the Ethnic Communities Council of Queensland (ECCQ)

Phone: **3844 9166**
Email: **health@eccq.com.au**
Website: **www.eccq.com.au/bbv**

eccq Ethnic Communities Council of Queensland

GESA Gastroenterological Society of Australia

This resource is produced by ECCQ with funding from Queensland Health in collaboration with Logan, Royal Brisbane and Women's, Mater, Princess Alexandra Hospitals, QuIHN and GESA

The information in this factsheet is general in nature.
Your health practitioner will advise specific instructions relevant to your individual health requirements. Published April 2024

Khmer/English

# របៀបលេបថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B នៅប្រទេសអូស្ត្រាលី

# How to Take Hepatitis B Medication in Australia



## Entecavir៖

- ជួនកាលគេហៅតាមម៉ាកបច្ចុប្បន្នរបស់វាថា Apotex ឬ Mylan។
- ត្រូវតែមានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកជាន់ខ្ពស់ដែលមានសុពលភាពដើម្បីទិញនៅឱសថស្ថាន។
- លេបមួយគ្រាប់ជារៀងរាល់ថ្ងៃជាមួយទឹក – វេជ្ជបណ្ឌិតរបស់អ្នកនឹងប្រាប់អ្នក ប្រសិនបើអ្នកត្រូវការដូសថ្នាំផ្សេង។
- អ្នកត្រូវលេបថ្នាំនេះនៅពេលគ្មានអាហារក្នុងពោះ - កុំបរិភោគអាហារ 2 ម៉ោងមុន និង 2 ម៉ោងក្រោយពីលេបថ្នាំ។
- មនុស្សមួយចំនួនយល់ឃើញថាវាងាយស្រួលជាងក្នុងការលេបថ្នាំនៅព្រឹកព្រហាម ហើយបន្ទាប់មកបរិភោគអាហារពេលព្រឹក 2 ម៉ោងក្រោយមក ឬលេបវាមុនពេលចូលគេងនៅពេលយប់ (កុំបរិភោគ 2 ម៉ោងមុន)។
- អាចទិញបានក្នុងតម្លៃទាបជាមួយកាតមេឌីឃែរ (Medicare Card) ឬកាតសម្បទាន (Concession Card) ដូចជាកាតថែទាំសុខភាព (Health Care Card)។
- អាចទិញបានជាមួយវេជ្ជបញ្ជាឯកជន (តម្លៃពេញ) ប្រសិនបើអ្នកមិនមានកាត Medicare។ សូមពិភាក្សាអំពីតម្លៃថ្នាំជាមួយវេជ្ជបណ្ឌិត ឬឱសថការីរបស់អ្នក។

## Tenofovir Disoproxil Fumarate (TDF)៖

- ជួនកាលគេហៅតាមម៉ាកបច្ចុប្បន្នរបស់វា - Viread។
- ត្រូវតែមានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកជាន់ខ្ពស់ដែលមានសុពលភាពដើម្បីទិញនៅឱសថស្ថាន។
- លេបមួយគ្រាប់ជារៀងរាល់ថ្ងៃជាមួយទឹក – វេជ្ជបណ្ឌិតរបស់អ្នកនឹងប្រាប់អ្នក ប្រសិនបើអ្នកត្រូវការដូសថ្នាំផ្សេង។
- អាចលេបជាមួយអាហារ។
- មានសុវត្ថិភាពក្នុងការប្រើនៅពេលមានផ្ទៃពោះ។
- អាចទិញបានក្នុងតម្លៃទាបជាមួយកាតមេឌីឃែរ (Medicare Card) ឬកាតសម្បទាន (Concession Card) ដូចជាកាតថែទាំសុខភាព (Health Care Card)។
- អាចទិញបានជាមួយវេជ្ជបញ្ជាឯកជន (តម្លៃពេញ) ប្រសិនបើអ្នកមិនមានកាត Medicare។ សូមពិភាក្សាអំពីតម្លៃថ្នាំជាមួយវេជ្ជបណ្ឌិត ឬឱសថការីរបស់អ្នក។



## Entecavir:

- Sometimes called by its current brand names Apotex or Mylan.
- Must have a valid doctor or nurse practitioner prescription to buy at a pharmacy.
- Take one tablet once a day with water – your doctor will let you know if you need a different dose.
- You need to take this medication on an empty stomach – do not eat for 2 hours before and 2 hours after taking the medication.
- Some people find it easier to take the tablet first thing in the morning, and then eat breakfast 2 hours later; or take it before going to bed at night (do not eat for 2 hours before).
- Available at a lower cost with a Medicare Card or Concession Card such as Health Care Card.
- Available on a private prescription (full price) if you do not have a Medicare Card. Please discuss costs with your doctor or pharmacist.

## Tenofovir Disoproxil Fumarate (TDF):

- Sometimes called by its current brand name – Viread.
- Must have a valid doctor or nurse practitioner prescription to buy at a pharmacy.
- One tablet once a day with water – your doctor will let you know if you need a different dose.
- Can be taken with food.
- Safe to use in pregnancy.
- Available at a lower cost with a Medicare Card or Concession Card such as Health Care Card.
- Available on a private prescription (full price) if you do not have a Medicare Card. Please discuss costs with your doctor or pharmacist.



## Tenofovir Alafenamide (TAF)៖

- ជួនកាលគេហៅតាមម៉ាកបច្ចុប្បន្នរបស់វា - Vemlidy។
- ត្រូវតែមានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិតដែលមានសុពលភាព។
- លេបមួយគ្រាប់ជារៀងរាល់ថ្ងៃជាមួយទឹក – វេជ្ជបណ្ឌិតរបស់អ្នកនឹងប្រាប់អ្នក ប្រសិនបើអ្នកត្រូវការដូសថ្នាំផ្សេង។
- អាចលេបជាមួយអាហារ។
- បច្ចុប្បន្នមិនមានលក់ក្នុងតម្លៃទាបនៅក្នុងប្រទេសអូស្ត្រាលីទេ បើទោះបីជាអ្នកមានកាតមេឌីឃែរ (Medicare Card) ឬកាតសម្បទាន (Concession Card) ដូចជាកាតថែទាំសុខភាព (Health Care Card) ក៏ដោយ ដូច្នេះអ្នកនឹងត្រូវបង់ក្នុងតម្លៃពេញ។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬឱសថការីរបស់អ្នកអំពីតម្លៃ - ក៏អាចរកទិញបាននៅតាមអ៊ីនធឺណិតពីក្រៅប្រទេសផងដែរ។

## ចំណុចសំខាន់ៗដែលត្រូវចងចាំ៖

- ជាទូទៅ ថ្នាំទាំងនេះគឺសម្រាប់លេបពេញមួយជីវិត ដូចគ្នានឹងថ្នាំសម្រាប់ជំងឺរ៉ាំរ៉ៃផ្សេងទៀតដែរ។
- លេបមួយគ្រាប់ជារៀងរាល់ថ្ងៃនៅពេលដូចគ្នាជាមួយទឹក។
- តើបានខកខានលេបថ្នាំឬ? សូមលេបថ្នាំដែលបានខកខាននោះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននៅពេលអ្នកចងចាំ ប្រសិនបើវានៅថ្ងៃតែមួយ។ បន្ទាប់មក លេបថ្នាំធម្មតារបស់អ្នកនៅថ្ងៃបន្ទាប់។
- កុំលេបថ្នាំ 2 ដូសក្នុងពេលតែមួយ ឬក្នុងថ្ងៃតែមួយ។
- កុំចែករំលែកថ្នាំរបស់អ្នកជាមួយមនុស្សផ្សេងទៀត ដូចជាសមាជិកគ្រួសារ ឬមិត្តភក្តិរបស់អ្នក។
- ថ្នាំទាំងនេះមានផលប៉ះពាល់បន្ទាប់បន្សំតិចតួចណាស់។ មនុស្សមួយចំនួនអាចជួបប្រទះការឈឺក្បាលបន្តិចបន្តួច ដំណើរចង់ក្អួត អស់កម្លាំងជាដើម នៅពេលចាប់ផ្តើមលេបថ្នាំ។ ប្រសិនបើអ្នកមានរោគសញ្ញានានាដែលធ្វើឱ្យអ្នកព្រួយបារម្ភ សូមកុំឈប់លេបថ្នាំដោយមិនបានពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកជាមុន។
- ត្រូវប្រាកដថាអ្នកមិនប្រើថ្នាំរហូតទាល់តែអស់។ ការបញ្ឈប់ និងចាប់ផ្តើមលេបថ្នាំអាចបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរដល់ថ្លើម និងសុខភាពរបស់អ្នក។ ប្រសិនបើអ្នកអស់ថ្នាំ សូមទាក់ទងវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកភ្លាម។
- កុំបញ្ឈប់លេបថ្នាំក្នុងពេលកំពុងតមអាហារ ឧទាហរណ៍ ក្នុងអំឡុងពេលរ៉ាម៉ាដាន (Ramadan) ឬលេបថ្នាំផ្សេងទៀតដូចជាថ្នាំផ្សះជាដើម។ ប្រសិនបើអ្នកមិនប្រាកដទេ សូមសួរវេជ្ជបណ្ឌិត គិលានុបដ្ឋាក ឬឱសថការីរបស់អ្នក។
- ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកមុនពេលអ្នកធ្វើដំណើរ ព្រោះអ្នកនឹងត្រូវការថ្នាំគ្រប់គ្រាន់ក្នុងពេលធ្វើដំណើរទៅកាន់ទីឆ្ងាយ។ អ្នកប្រហែលជាត្រូវការលិខិតពីវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីយកថ្នាំនានាទៅកាន់ប្រទេសមួយផ្សេងទៀត។

## Tenofovir Alafenamide (TAF):

- Also called by its current brand name – Vemlidy.
- Must have a valid doctor prescription.
- One tablet once a day with water – your doctor will let you know if you need a different dose.
- Can be taken with food.
- Not currently available at a lower cost in Australia even if you have a Medicare Card or Concession Card such as Health Care Card, therefore, you will pay full price. Talk to your doctor or pharmacist about the cost – may also be available online for purchase from overseas.

## Important things to remember:

- These medications are generally for life-long term use, like for other chronic health conditions.
- Take one tablet every day at the same time with water.
- Missed a tablet? Take the missed tablet as soon as possible when you remember if it is the same day. Then, take your normal tablet the next day.
- Do not take 2 doses at one time or on the same day.
- Do not share your medication with other people, such as your family members or friends.
- These medications have very few side effects. Some people may experience mild headaches, nausea, tiredness etc., when starting the medication. If you have symptoms that worry you, do not stop taking the medications without first talking to your doctor or nurse.
- Make sure you do not run out of medications; stopping and starting medications can cause serious problems for your liver and health. If you do run out of medications contact your doctor or nurse immediately.
- Do not stop medications whilst fasting e.g., during Ramadan or if taking other medications such as antibiotics etc. If you are unsure, ask your doctor, nurse, or pharmacist.
- Discuss with your doctor before you travel as you will need sufficient medications whilst away. You may need a letter from your doctor to carry the medications into another country.